


# ការសិក្សាយកសញ្ញាប័ត្រឌីផ្លូម៉ា ៖ ចាប់ពីឆ្នាំសិក្សា 2009 តទៅ

សិស្សានុសិស្សទាំងអស់ត្រូវការគ្រឹះរឹងមាំក្នុងជំនាញនៃការអាន, ការសរសេរ, និងគណិតសាស្ត្រសំរាប់ជាស្ពានទៅរកវិជ្ជាជីវៈផ្សេងៗ ដែលពួកគេចង់បានក្រោយបញ្ចប់ កម្មសិក្សាពីសាលាហៃស្គូល។ សេចក្តីតម្រូវទូទាំងរដ្ឋមួយចំនួនត្រូវបានចងក្រងស្ថាបនាឡើង ដើម្បីធ្វើយ៉ាងណាធានាថា សិស្សានុសិស្សទាំងអស់មានគ្រឹះរឹងមាំនេះ។

សំរាប់ការបញ្ចប់កម្មសិក្សានៃឆ្នាំសិក្សា 2009-2012, សិស្សានុសិស្សត្រូវតែប្រឡងជាប់វិញ្ញាសាឈ្មោះ Washington Assessment of Student Learning (ការប៉ាន់ប្រមាណរបស់រដ្ឋវ៉ាស៊ីនលើការសិក្សារៀនសូត្ររបស់សិស្ស – WASL) ក្នុងជំនាញនៃការអាន និងការសរសេរ, វិញ្ញាសារដ្ឋអនុម័តជំនួស WASL ណាមួយ, ឬវិញ្ញាសាប៉ាន់ប្រមាណសិស្សានុសិស្សក្នុងកម្មវិធីអប់រំពិសេសណាមួយ។ សិស្សានុសិស្សអាចជួបតាមសេចក្តីតម្រូវផ្នែកគណិតសាស្ត្ររបស់រដ្ឋតាមរយៈការប្រឡងជាប់វិញ្ញាសា WASL នៃគណិតសាស្ត្រហៃស្គូល, វិញ្ញាសារដ្ឋអនុម័តជំនួសណាមួយ, ឬវិញ្ញាសាប៉ាន់ប្រមាណសិស្សានុសិស្សក្នុងកម្មវិធីអប់រំពិសេសណាមួយ, **ឬក៏,** ត្រូវបន្តសិក្សាសន្សំ យកពិន្ទុក្រេឌិត ហើយត្រូវប្រឡងប្រចាំឆ្នាំនូវវិញ្ញាសាប៉ាន់ប្រមាណផ្នែកគណិតសាស្ត្រទៅតាមករណីសមរម្យណាមួយ រហូតទាល់តែពួកគេបញ្ចប់កម្មសិក្សាជាស្ថាពរ។

សិស្សានុសិស្សក្នុងឆ្នាំសិក្សា 2013 គឺជាសិស្សដំបូងគេបង្អស់ដែលត្រូវបានតម្រូវឲ្យប្រឡងជាប់នូវវិញ្ញាសា WASL ផ្នែកវិទ្យាសាស្ត្រ និងគណិតសាស្ត្រ, វិញ្ញាសារដ្ឋ អនុម័តជំនួសណាមួយ, ឬវិញ្ញាសាប៉ាន់ប្រមាណសិស្សានុសិស្សក្នុងកម្មវិធីអប់រំពិសេសណាមួយ។ ឆ្នាំសិក្សា 2013 នឹងមានជម្រើសបន្ថែមមួយទៀតក្នុងការរើសយក វិញ្ញាសាប្រឡងមុខវិជ្ជាសិក្សាបញ្ចប់គណិតសាស្ត្រ (math end-of-course exams)។ ចាប់ផ្តើមក្នុងឆ្នាំសិក្សា 2014, វិញ្ញាសា WASL ផ្នែកគណិតសាស្ត្រហៃស្គូល នឹងត្រូវដាក់ជំនួសដោយវិញ្ញាសាប្រឡងមុខវិជ្ជាសិក្សាបញ្ចប់គណិតសាស្ត្រ, ដែលជាសេចក្តីតម្រូវសំរាប់ការបញ្ចប់កម្មសិក្សាហៃស្គូល។ សំរាប់ព័ត៌មានពិស្តារបន្ថែមអំពី បញ្ហានៃការបញ្ចប់កម្មសិក្សាហៃស្គូល, សូមមើល ៖ http://www.k12.wa.us/GraduationRequirements/default.aspx ។

## សេចក្តីតម្រូវនៃការបញ្ចប់កម្មសិក្សាហៃស្គូលរបស់រដ្ឋវ៉ាស៊ីនតោន

(ការកំណត់មើលឆ្នាំសិក្សាដំបូងដែលសិស្សចាប់ចូលរៀនថ្នាក់ទីប្រាំបួន)

| ឆ្នាំសិក្សា 2009-2012<br>(សិស្សថ្នាក់ទី 9-12 ក្នុងឆ្នាំសិក្សា 2008-09) | ឆ្នាំសិក្សា 2013<br>(សិស្សថ្នាក់ទី 9-12 ក្នុងឆ្នាំសិក្សា 2009-10) | ឆ្នាំសិក្សា 2014<br>(សិស្សថ្នាក់ទី 9-12 ក្នុងឆ្នាំសិក្សា 2010-11) |
|---|---|---|
| **ការអាន និងការសរសេរ**<br>**ជាប់** WASL ការអាននិងការសរសេរហៃស្គូល ឬវិញ្ញាសាប៉ាន់ប្រមាណសិស្សានុសិស្សក្នុងកម្មវិធីអប់រំពិសេស។<br>--ឬ--<br>**ជាប់**ការអាននិងការសរសេរនៃCertificate of Academic Achievement Option (វិញ្ញាសារដ្ឋអនុម័តជំនួស)។ * | **ការអាន និងការសរសេរ**<br>**ជាប់** WASL ការអាននិងការសរសេរហៃស្គូល ឬវិញ្ញាសាប៉ាន់ប្រមាណសិស្សានុសិស្សក្នុងកម្មវិធីអប់រំពិសេស។<br>--ឬ--<br>**ជាប់**ការអាននិងការសរសេរនៃCertificate of Academic Achievement Option (វិញ្ញាសារដ្ឋអនុម័តជំនួស)។ * | **ការអាន និងការសរសេរ**<br>**ជាប់** WASL ការអាននិងការសរសេរហៃស្គូល ឬវិញ្ញាសាប៉ាន់ប្រមាណសិស្សានុសិស្សក្នុងកម្មវិធីអប់រំពិសេស។<br>--ឬ--<br>**ជាប់**ការអាននិងការសរសេរនៃ Certificate of Academic Achievement Option (វិញ្ញាសារដ្ឋអនុម័តជំនួស)។ * |
| **គណិតសាស្ត្រ**<br>**ជាប់** WASL ផ្នែកគណិតសាស្ត្រហៃស្គូល ឬវិញ្ញាសាប៉ាន់ប្រមាណសិស្សានុសិស្សក្នុងកម្មវិធីអប់រំពិសេស។<br>--ឬ--<br>**ជាប់**គណិតសាស្ត្រនៃ Certificate of Academic Achievement Option (វិញ្ញាសារដ្ឋអនុម័តជំនួស)។ *<br>--ឬ—<br>**សិក្សាសន្សំ**ពិន្ទុក្រេឌិតចំនួនពីរពិន្ទុ (ឬពិន្ទុក្រេឌិតដែលស្មើនឹងមុខវិជ្ជាសិក្សាផ្នែកវិជ្ជាជីវៈ និងបច្ចេកទេស) ក្រោយពី ថ្នាក់ទី 10 **ហើយ**ត្រូវប្រឡង WASL ឡើងវិញ ឬវិញ្ញាសារដ្ឋអនុម័តសំរាប់ប៉ាន់ប្រមាណគណិតសាស្ត្រប្រចាំឆ្នាំ។ (សិស្សានុសិស្សត្រូវតែប្រឡងជាប់ថ្នាក់គណិតសាស្ត្រ, មិនមែនវិញ្ញាសាប៉ាន់ប្រមាណទេ, ដើម្បីអាចយកសញ្ញាប័ត្រ ឌីផ្លូម៉ាបាន។) | **គណិតសាស្ត្រ**<br>**ជាប់** WASL ផ្នែកគណិតសាស្ត្រហៃស្គូល, ឬវិញ្ញាប្រឡងមុខវិជ្ជាសិក្សាបញ្ចប់, ឬវិញ្ញាសាប៉ាន់ប្រមាណសិស្សានុសិស្សក្នុងកម្មវិធីអប់រំពិសេស។<br>--ឬ--<br>**ជាប់**គណិតសាស្ត្រនៃ Certificate of Academic Achievement Option (វិញ្ញាសារដ្ឋអនុម័តជំនួស)។ * | **គណិតសាស្ត្រ**<br>**ជាប់**វិញ្ញាប្រឡងមុខវិជ្ជាសិក្សាបញ្ចប់ ឬវិញ្ញាសាប៉ាន់ប្រមាណសិស្សានុសិស្សក្នុងកម្មវិធីអប់រំពិសេស។<br>--ឬ--<br>**ជាប់**គណិតសាស្ត្រនៃ Certificate of Academic Achievement Option (វិញ្ញាសារដ្ឋអនុម័តជំនួស)។ * |
| | **វិទ្យាសាស្ត្រ**<br>**ជាប់**វិញ្ញាសា WASL វិទ្យាសាស្ត្រហៃស្គូល ឬវិញ្ញាសាមើលសិស្សានុសិស្សក្នុងកម្មវិធីអប់រំពិសេស។<br>--ឬ--<br>**ជាប់**វិញ្ញាសា Certificate of Academic Achievement Option (វិញ្ញាសារដ្ឋអនុម័តជំនួស)។ * | **វិទ្យាសាស្ត្រ**<br>**ជាប់**វិញ្ញាសា WASL វិទ្យាសាស្ត្រហៃស្គូល ឬវិញ្ញាសាមើលសិស្សានុសិស្សក្នុងកម្មវិធីអប់រំពិសេស។<br>--ឬ--<br>**ជាប់**វិញ្ញាសា Certificate of Academic Achievement Option (វិញ្ញាសារដ្ឋអនុម័តជំនួស)។ * |
| **សេចក្តីតម្រូវផ្សេងៗ**<br>**ត្រូវជួបតាម**គ្រប់ទាំងសេចក្តីតម្រូវនៃការបញ្ចប់កម្មសិក្សាផ្សេងៗទៀតរបស់រដ្ឋ និងមណ្ឌលសិក្សាធិការដ្ឋាន ៖ កម្ម វិធី Culminating Project, High School និងផែនការ Beyond Plan ព្រមទាំងសេចក្តីតម្រូវនៃពិន្ទុក្រេឌិតប្រចាំ មូលដ្ឋានទានា។ | **សេចក្តីតម្រូវផ្សេងៗ**<br>**ត្រូវជួបតាម**គ្រប់ទាំងសេចក្តីតម្រូវនៃការបញ្ចប់កម្មសិក្សាផ្សេងៗទៀតរបស់រដ្ឋ និងមណ្ឌលសិក្សាធិការដ្ឋាន ៖ កម្ម វិធី Culminating Project, High School និងផែនការ Beyond Plan ព្រមទាំងសេចក្តីតម្រូវនៃពិន្ទុក្រេឌិតប្រចាំ មូលដ្ឋានទានា។ | **សេចក្តីតម្រូវផ្សេងៗ**<br>**ត្រូវជួបតាម**គ្រប់ទាំងសេចក្តីតម្រូវនៃការបញ្ចប់កម្មសិក្សាផ្សេងៗទៀតរបស់រដ្ឋ និងមណ្ឌលសិក្សាធិការដ្ឋាន ៖ កម្មវិធី Culminating Project, High School និងផែនការ Beyond Plan ព្រមទាំងសេចក្តីតម្រូវនៃពិន្ទុក្រេឌិតប្រចាំមូលដ្ឋាន ទានា។ |

* សិស្សានុសិស្សត្រូវតែប្រឡងវិញ្ញាសា WASL ហៃស្គូលម្តង មុននឹងអាចប្រើវិញ្ញាសារដ្ឋអនុម័តជំនួយណាមួយបាន លើកលែងតែពួកគេជាសិស្សថ្មីក្នុងថ្នាក់ទី 11 និង 12។

**Updated September** 2008

# ស្វែងយល់បន្ថែមទៀតអំពីសេចក្តីតម្រូវនៃការបញ្ចប់កម្មសិក្សា និងវិញ្ញាសា WASL

## អំពីវិញ្ញាបនប័ត្រ Certificate of Academic Achievement និង Certificate of Individual Achievement

- សិស្សានុសិស្សដែលប្រឡងជាប់វិញ្ញា WASL នៃការអាន, ការសរសេរ, និងគណិតសាស្រ្តមានកិត្តិយសទទួល Certificate of Academic Achievement (វិញ្ញាបនប័ត្រនៃការ សម្រេចកម្មសិក្សា – CAA) ឬ Certificate of Individual Achievement (វិញ្ញាបនប័ត្រនៃការសម្រេចឯកត្តជន – CIA)។ សិស្សានុសិស្សដែលមានកិត្តិយសទទួលវិញ្ញាបនប័ត្រណាមួយខាងលើនឹងត្រូវគេចុះជាកំណត់ត្រាសម្គាល់កិត្តិនាមនោះនៅក្នុងឯកសារកំណត់ហេតុកម្មសិក្សា (transcript) របស់ពួកគេ។
- Certificate of Academic Achievement – មិនទាន់ជាសេចក្តីតម្រូវសំរាប់ការបញ្ចប់កម្មសិក្សាទេ ទាល់តែដល់ឆ្នាំ 2013, ប៉ុន្តែសិស្សានុសិស្សអាចប្រឡងយកវិញ្ញាបនប័ត្រនេះបានតាមរយៈការប្រឡងឲ្យជាប់ WASL នៃការអាន, ការសរសេរ, និងគណិតសាស្រ្ត ឬយក Certificate of Academic Achievement Option (វិញ្ញាបនប័ត្រនៃជម្រើសការសម្រេចកម្មសិក្សា – វិញ្ញាសារដ្ឋអនុម័តជំនួស) ក្នុងការអាន, ការសរសេរ, និងគណិតសាស្រ្ត។
- Certificate of Individual Achievement – សំរាប់តែសិស្សានុសិស្សក្នុងកម្មវិធីអប់រំពិសេសប៉ុណ្ណោះ។ មិនទាន់ជាសេចក្តីតម្រូវសំរាប់ការបញ្ចប់កម្មសិក្សាទេ ទាល់តែដល់ឆ្នាំ 2013, ប៉ុន្តែសិស្សានុសិស្សអាចប្រឡងយកវិញ្ញាបនប័ត្រនេះបានតាមរយៈការប្រឡងឲ្យជាប់វិញ្ញាសា WASL-Basic, WAAS-Portfolio, WAAS-DAW (Developmentally Appropriate WASL – WASL សម្រួលតាមលក្ខណៈសមរម្យសំរាប់ជនពិការ) ឬវិញ្ញាសា Locally Determined Assessment ក្នុងការអាន, ការ សរសេរ, និងគណិតសាស្រ្ត។
- សិស្សានុសិស្សក្នុងឆ្នាំសិក្សា 2009-2012 ដែលសិក្សាសន្សំពិន្ទុក្រេឌិតបន្តិចម្តងៗទាល់តែបញ្ចប់កម្មសិក្សា, តែមិនបានប្រឡងជាប់វិញ្ញាសា WASL ផ្នែកគណិតសាស្រ្ត ឬវិញ្ញាសាប៉ាន់ប្រមាណគណិតសាស្រ្តតាមការអនុម័តិណាមួយនោះ, នៅតែមានលក្ខណសម្បត្តិសិក្សាយកសញ្ញាប័ត្រឌីផ្លូម៉ាដដែល ប៉ុន្តែពួកគេមិនអាចទទួលវិញ្ញាបនប័ត្រណាមួយបានទេ។
- ប្រព័ន្ធអនុគ្រោះមានបម្រុងជូនបណ្តាសិស្សានុសិស្សដែលត្រូវផ្ទេរទៅសិក្សាក្នុងសាលាហៃស្គូលសាធារណៈក្នុងថ្នាក់ទី 11 និង 12 ពីរដ្ឋផ្សេងៗ និងប្រទេសក្រៅ។ សិស្សានុសិស្ស ដែលមានជំនាញ ប៉ុន្តែមិនអាចបង្ហាញជំនាញទាំងនោះនៅលើវិញ្ញាសា WASL, ឬវិញ្ញាសារដ្ឋអនុម័តជំនួសណាមួយបាន គឺអាចដាក់ពាក្យសុំធ្វើ ឧទ្ធរណ៍ករណីពិសេសដែលមិន អាចជៀសវាងបាន។ សិស្សានុសិស្សដែលបានទទួលជោគជ័យក្នុងការសុំធ្វើឧទ្ធរណ៍អាចទទួលសញ្ញាប័ត្រឌីផ្លូម៉ាបាន ប៉ុន្តែយកវិញ្ញាបនប័ត្រមិនបានទេ។

## អំពីវិញ្ញាសា WASL ហៃស្គូល

- សិស្សានុសិស្សមានឱកាសទទួលមូលនិធិរដ្ឋចំនួនប្រាំដងនៅក្នុងកំឡុងពេលសិក្សាក្នុងសាលាហៃស្គូល ដើម្បីប្រឡង WASL តាមមាតិកានិមួយ ៖ ការអាន, ការសរសេរ, និង គណិតសាស្រ្ត។ មាតិកាវិទ្យាសាស្រ្តមិនទាន់មានចុះនៅក្នុងកម្មវិធីប្រឡងខែសីហានៅឡើយទេ។ មាតិកាកម្មវិធីនឹងត្រូវមានការផ្លាស់ប្តូរពេលសេចក្តីតម្រូវនៃការបញ្ចប់កម្មសិក្សា ហៃស្គូលនៃឆ្នាំសិក្សា 2013 ឈានមកដល់។
- សិស្សានុសិស្សត្រូវប្រឡងឲ្យជាប់ពិន្ទុស្តង់ដកម្រិត Level 3 ឬ Level 4 ។
- ការប្រឡងវិញ្ញាសា WASL ត្រូវប្រព្រឹត្តទៅនៅខែមីនា/មេសា និងខែសីហារៀងរាល់ឆ្នាំ។
- នីតិវិធីនៃការសុំធ្វើឧទ្ធរណ៍ពិន្ទុស្តង់ ៖ ឪពុកម្តាយ/អ្នកអាណាព្យាបាល, ក្រោយពីបានពិនិត្យមើលវិញ្ញាប្រឡងរបស់សិស្សពួកគេរួចហើយ, ពួកគេអាចដាក់ពាក្យសុំធ្វើឧទ្ធរណ៍ពិន្ទុស្តង់ ណាមួយជាមួយនឹងរដ្ឋបាន។
- ដើម្បីស្វែងយល់ព័តិមានពិស្តារបន្ថែមអំពីវិញ្ញាសា WASL, សូមមើល ៖ http://www.waslinfo.com ។

## អំពីវិញ្ញាសារដ្ឋអនុម័តជំនួស WASL

- សិស្សានុសិស្សដែលមានជំនាញ ប៉ុន្តែមិនអាចបង្ហាញជំនាញទាំងនោះនៅលើវិញ្ញាសា WASL បាន អាចប្រើវិញ្ញាសានៃវិញ្ញាបនប័ត្រ Certificate of Academic Achievement Options ឬវិញ្ញាសារដ្ឋអនុម័តជំនួសណាមួយបាន។
- សិស្សានុសិស្សអាចមានសិទ្ធិប្រើប្រាស់ជម្រើសវិញ្ញាសានានាបាន ក្រោយពីប្រឡង WASL ហៃស្គូលម្តងរួចហើយ។ សិស្សានុសិស្សដែលផ្ទេរពីរដ្ឋផ្សេង និងប្រទេសក្រៅ ទៅសិក្សាក្នុងសាលាហៃស្គូលសាធារណៈថ្នាក់ទី 11 និង 12, និងសិស្សានុសិស្សដែលផ្ទេរពីសាលាឯកជនក្នុងរដ្ឋ ឬពីមូលដ្ឋានអប់រំនៅតាមផ្ទះ (ក្រោមស្ថានភាពជាក់លាក់ នានា) ទៅសិក្សាក្នុងសាលាហៃស្គូលសាធារណៈថ្នាក់ទី 12, អាចមានសិទ្ធិប្រើប្រាស់វិញ្ញាសា CAA Options បានភ្លាម ដោយមិនចាំបាច់ប្រឡងវិញ្ញាសា WASL ជាមុនទេ។
- វិញ្ញាសានៃវិញ្ញាបនប័ត្រ Certificate of Academic Achievement Options មានដូចតទៅ ៖
  - Collection of Evidence (ការប្រមូលផ្តុំភស្តុតាង) – សិស្សានុសិស្សត្រូវប្រមូលផ្តុំក្រដាសស្នាមគំរូសិក្សាក្នុងថ្នាក់ដោយមានជំនួយពីលោកគ្រូ-អ្នកគ្រូ។ ការប្រមូលផ្តុំក្រដាសស្នាមសំរាប់កម្មវិធីអប់រំវិជ្ជាជីវៈ និងបច្ចេកទេសអាចរួមមានទូវក្រដាសស្នាមពីកម្មវិធីនានាដែលពួកគេសិក្សា។ រដ្ឋពិនិត្យឲ្យពិន្ទុស្តង់លើកញ្ចប់ភស្តុតាងទាំងនេះពីរ ដងក្នុងមួយឆ្នាំ។
  - Fee Waivers (ការចេញថ្លៃអនុគ្រោះ) មានបម្រុងជូនសិស្សានុសិស្សដែលមានលក្ខណសម្បត្តិប្រឡងវិញ្ញាសាប៉ាន់ប្រមាណ SAT, ACT, និង AP ។
  - SAT ឬ ACT – សិស្សានុសិស្សអាចប្រើពិន្ទុស្តង់គណិតសាស្រ្ត, ការអាន, ឬភាសាអង់គ្លេស និងការសរសេរពីលទ្ធផលប្រឡងត្រៀមចូលមហាវិទ្យាល័យ។ ពិន្ទុដ៏តិចបំផុត គឺ ៖ **ការអាន** – SAT: 350 ACT: 13 ។ **ការសរសេរ** – SAT: 380 ACT: 15 ។ **គណិតសាស្រ្ត** – SAT: 470 ACT: 19 ។
  - Advanced Placement (ការប្រឡងស្ទង់មើលកម្រិតថ្នាក់ជាមុន – AP) – សិស្សានុសិស្សអាចប្រើពិន្ទុស្តង់បីឬខ្ពស់ជាងនេះពីលទ្ធផលប្រឡង AP ជម្រើស ៖ **គណិត សាស្រ្ត** (គណនាអត្យាណូ ឬស្ថិតិលេខ), **ការសរសេរ** (ភាសាអង់គ្លេស និងការតែងសេចក្តី); និង**ការអាន** (អក្សរសិល្បអង់គ្លេស និងការតែងសេចក្តី, ម៉ាក្រូសេដ្ឋកិច្ច, មីក្រូសេដ្ឋកិច្ច, ចិត្តវិជ្ជា, ប្រវត្តិសាស្រ្តសហរដ្ឋអាមេរិក, ប្រវត្តិសាស្រ្តពិភពលោក, រដ្ឋាភិបាលនិងនយោបាយសហរដ្ឋអាមេរិក, ឬរដ្ឋាភិបាលនិងនយោបាយប្រៀបធៀប)។
- WASL/Grades Comparison (ការប្រៀបធៀបពិន្ទុក្រេឌ WASL) – សំរាប់តែសិស្សានុសិស្សក្នុងថ្នាក់ទី 12 ប៉ុណ្ណោះ។ ពិន្ទុក្រេឌរបស់សិស្សក្នុងមុខវិជ្ជាសិក្សាគណិតសាស្រ្ត និង/ឬមុខវិជ្ជាសិក្សាភាសាអង់គ្លេសត្រូវគេយកទៅប្រៀបធៀបនឹងពិន្ទុក្រេឌរបស់សិស្សឯទៀតៗ ដែលរៀនមុខវិជ្ជាសិក្សាដូចគ្នានេះដែរ **ហើយ**ដែលបានប្រឡងជាប់ WASL ហៃស្គូល។ ដើម្បីប្រើប្រាស់ជម្រើសនេះ, សិស្សានុសិស្សត្រូវតែមានពិន្ទុក្រេឌមធ្យមភាគ (Grade Point Average – GPA) សន្សំសរុបទាំងអស់ ឲ្យបានយ៉ាងតិចណាស់ 3.2 លើខ្នាតរង្វាស់នៃពិន្ទុក្រេឌ 4.0 ។
- ដើម្បីស្វែងយល់ព័តិមានពិស្តារបន្ថែមអំពីវិញ្ញាសារដ្ឋអនុម័តជំនួស, សូមមើល ៖ http://www.k12.wa.us/assessment/CAAoptions/default.aspx ។

## អំពីការប៉ាន់ប្រមាណសំរាប់សិស្សានុសិស្សក្នុងកម្មវិធីអប់រំពិសេស

- សិស្សានុសិស្សក្នុងកម្មវិធីអប់រំពិសេសអាចប្រឡងវិញ្ញសា WASL ហៃស្គូលដោយមាន ឬក៏ដោយគ្មានការសម្របសម្រួល ឬការប្រើប្រាស់វិញ្ញាសាមួយពីចំណោមបណ្តាវិញ្ញាសា នៃវិញ្ញាបនប័ត្រ Certificate of Academic Achievement Options ។
- ជម្រើសទាំងប៉ុន្មានខាងក្រោមនេះត្រូវបានបម្រុងជូនផងដែរ ៖
  - WASL-Basic (WASL-មូលដ្ឋាន) – សិស្សានុសិស្សប្រឡងវិញ្ញាសា WASL ហៃស្គូល – ដោយមាន ឬក៏ដោយគ្មានការសម្របសម្រួល – ប៉ុន្តែក្រុមអង្គភាព IEP ជួយលៃសម្រួលលក្ខណវិនិច្ឆ័យនៃការជាប់ការប្រឡងចេញពីវិញ្ញាសាជំនាញប៉ិនប្រសប់ Proficient (Level 3) ទៅវិញ្ញាសាមូលដ្ឋាន Basic (Level 2) ។
  - Washington Alternate Assessment System Portfolio (ផលប័ត្រប្រព័ន្ធប៉ាន់ប្រមាណជំនួសរបស់រដ្ឋវ៉ាស៊ីនតោន – WAAS Portfolio) – សិស្សានុសិស្សដែលមិនអាចប្រឡងវិញ្ញាសាដោយការប្រើប៊ិច និងខ្មៅដៃ ត្រូវបង្ហាញជំនាញការ និងចំណេះដឹងនានារបស់ពួកគេតាមរយៈការបង្ហាញកញ្ចប់ភស្តុតាងនៃការប្រមូលផ្តុំក្រដាសស្នាមការងារ របស់ពួកគេ។
  - Developmentally Appropriate WASL (វិញ្ញាសា WASL តាមកម្រិតសតិបញ្ញា – WAAS-DAW) – សិស្សានុសិស្សក្នុងថ្នាក់ទី 11 និង 12 តែប៉ុណ្ណោះ ប្រឡងវិញ្ញាសា WASL – ដោយមាន ឬក៏ដោយគ្មានការសម្របសម្រួល – តាមកម្រិតថ្នាក់ដែលសមរម្យទៅតាមសមត្ថភាពរបស់ពួកគេ។ សិស្សានុសិស្សប្រឡងជាប់វិញ្ញាសា DAW តាមការ សម្រេចបានទូវជំនាញប៉ិនប្រសប់ Proficient (Level 3) លើវិញ្ញាសាប្រឡងនិមួយ។
  - Locally Determined Assessments (ការប៉ាន់ប្រមាណតាមសេចក្តីកំណត់ប្រចាំមូលដ្ឋាន) – សំរាប់សិស្សានុសិស្សក្នុងថ្នាក់ទី 12 ដែលត្រូវការនូវបទដ្ឋាននៃការសម្រេច តាមកំណែសម្រួល។
  - Awareness Level Waiver (ការអនុគ្រោះតាមកម្រិតសម្បជញ្ញៈ) – មានបម្រុងសំរាប់សិស្សានុសិស្សដែលត្រូវបានធ្វើរោគវិនិច្ឆ័យឃើញថា អាចអនុវត្តកិច្ចការបានត្រឹមតែកម្រិត“សម្បជញ្ញៈយល់ដឹង”ណាមួយប៉ុណ្ណោះ។
- ដើម្បីស្វែងយល់ព័តិមានពិស្តារបន្ថែមអំពីការប៉ាន់ប្រមាណនៃការអប់រំពិសេស, សូមមើល ៖ http://www.k12.wa.us/assessment/altassess.aspx ។